ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី
លេខ : ២២៧ ឯក

# ប្រកាស
## ស្តីពី
## ការបង្កើតលេខាធិការដ្ឋានគ្រប់គ្រងគ្រោះមហន្តរាយនៃទីស្តីការគណៈរដ្ឋមន្ត្រី

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧១៥/០០៧ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៥/១១៤១ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
- បានឃើញអនុក្រឹត្យលេខ១១៦ អនក្រ.បក ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃទីស្តីការគណៈរដ្ឋមន្ត្រី
- យោងតាមការចាំបាច់

## សម្រេច

**ប្រការ១.-**

បង្កើតលេខាធិការដ្ឋានគ្រប់គ្រងគ្រោះមហន្តរាយនៃទីស្តីការគណៈរដ្ឋមន្ត្រី ដែលមានសមាសភាពដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១- ឯកឧត្តម | **ជ្រា សុចិន្តា** | រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | ប្រធាន |
| ២- ឯកឧត្តម | **យិន យុនផយ** | អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | អនុប្រធាន |
| ៣- លោក | **លី សុធីរ័ត្ន** | អគ្គនាយករងនៃអគ្គនាយកដ្ឋានផលិតកម្ម រៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ៤- លោកស្រី | **ពេជ្រ ចាន់ណារ៉ត្រី** | អគ្គនាយករងនៃអគ្គនាយកដ្ឋានសម្របសម្រួលកិច្ចការផ្ទៃក្នុង | សមាជិកា |
| ៥- លោក | **សាត់ សាម៉ឺឌី** | អនុប្រធាននាយកដ្ឋានមហាផ្ទៃការពារជាតិ យុត្តិធម៌ និងស្ថាប័នរដ្ឋធម្មនុញ្ញ នៃអគ្គនាយដ្ឋានសម្របសម្រួលកិច្ចការផ្ទៃក្នុង | សមាជិក។ |

**ប្រការ២.-**

លេខាធិការដ្ឋានគ្រប់គ្រងគ្រោះមហន្តរាយនៃទីស្តីការគណៈរដ្ឋមន្ត្រី មានភារកិច្ចដូចខាងក្រោម៖

- រៀបចំនីតិវិធីនិងគោលការណ៍សម្រាប់អនុវត្តក្របខណ្ឌការងារ គ្រប់គ្រងគ្រោះមហន្តរាយក្នុងទីស្តីការគណៈរដ្ឋមន្ត្រី សម្រាប់មុនពេល ក្នុងពេល និងក្រោយពេលគ្រោះមហន្តរាយ

- សម្របសម្រួលការបញ្ជ្រាបការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ទៅក្នុងផែនការរយៈពេលវែង ផែនការប្រចាំឆ្នាំ និងផែនការសកម្មភាពការងារទៅក្នុងអង្គភាពពាក់ព័ន្ធក្រោមចំណុះទីស្តីការគណៈរដ្ឋមន្ត្រី
- រៀបចំផែនការត្រៀមបម្រុងសម្រាប់ការឆ្លើយតប សង្គ្រោះបន្ទាន់ និងស្តារឡើងវិញ
- សម្របសម្រួលឱ្យមានការលើកគម្រោងថវិកា និងគាំទ្រថវិកាដល់ការអនុវត្តផែនការគ្រប់គ្រងគ្រោះមហន្តរាយដែលបានបញ្ជ្រាបក្នុងទីស្តីការគណៈរដ្ឋមន្ត្រី
- ចូលរួមរៀបចំផែនការសកម្មភាពជាតិសម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ដើម្បីបន្សុីសកម្មភាពការគ្រប់គ្រងគ្រោះមហន្តរាយរបស់ក្រសួង ស្ថាប័ន ទៅក្នុងផែនការសកម្មភាពជាតិ
- ចូលរួមសម្របសម្រួល និងធ្វើប្រតិបត្តិការឆ្លើយតបគ្រោះអាសន្ន និងស្តារឡើងវិញក្រោយគ្រោះមហន្តរាយ
- ចូលរួមជាមួយគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយក្នុងការបណ្តុះបណ្តាលលើការគ្រប់គ្រងគ្រោះមហន្តរាយ អនុវត្តការប៉ាន់ប្រមាណការខូចខាត បាត់បង់ និងសេចក្តីត្រូវការពីគ្រោះមហន្តរាយក្នុងវិស័យរបស់ខ្លួន និងតាមដានត្រួតពិនិត្យ វាយតម្លៃលទ្ធផលដំណើរការរបស់អង្គភាពក្រោមឱវាទ
- សិក្សាស្រាវជ្រាវមុខសញ្ញាគ្រោះថ្នាក់ដោយធម្មជាតិឬមនុស្ស និងហានិភ័យផ្សេងៗ ដើម្បីដាក់ចេញវិធានការត្រៀមបង្ការ និងផ្តល់គោលការណ៍ណែនាំនៅតាមអង្គភាពក្រោមឱវាទ
- ផ្តល់ព័ត៌មាននិងរាយការណ៍ពីសភាពការណ៍ និងសកម្មភាពការងារគ្រប់គ្រងគ្រោះមហន្តរាយរបស់ទីស្តីការគណៈរដ្ឋមន្ត្រី ជូនគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ។

**ប្រការ៣.-**

លេខាធិការដ្ឋាននេះមានក្រុមជំនួយការងារជាមន្ត្រីបង្គោល ដើម្បីសម្របសម្រួលនិងប្រាស្រ័យទាក់ទងជាប្រចាំជាមួយអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ដែលមានសមាសភាពដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១- ឯកឧត្តម | **ឃិន ឃុនផយ** | អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | ប្រធាន |
| ២- លោក | **លី សុធីរ័ត្ន** | អគ្គនាយករងនៃអគ្គនាយកដ្ឋានផលិតកម្ម រៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ៣-លោក | **សាត់ សាម៉ីឌី** | អនុប្រធាននាយកដ្ឋានមហាផ្ទៃការពារជាតិ យុត្តិធម៌ និងស្ថាប័នរដ្ឋធម្មនុញ្ញ នៃអគ្គនាយដ្ឋានសម្របសម្រួលកិច្ចការផ្ទៃក្នុង | សមាជិក។ |

**ប្រការ៤.-**

គ្រប់អគ្គនាយកដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានផលិតកម្ម រៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អគ្គនាយកនៃអគ្គនាយកដ្ឋានសម្របសម្រួលកិច្ចការផ្ទៃក្នុង ប្រធានអង្គភាព នាយកដ្ឋានចំណុះទីស្តីការគណៈរដ្ឋមន្ត្រី និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ចន្ទ ៩ កើត ខែ ផល្គុន ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី២ ខែ មីនា ឆ្នាំ២០២០

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**

**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន**

**កន្លែងទទួល ៖**

-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
-ក្រសួងមុខងារសាធារណៈ
-គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តមកិត្តិនីតិកោសលបណ្ឌិតឧបនាយករដ្ឋមន្ត្រីប្រចាំការ
-ដូចប្រការ៤
-ឯកសារ-កាលប្បវត្តិ